# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៦ ស្តីពីការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ចំនួន ១៩ រូប ១៧៩

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៧ ស្តីពីការតែងតាំងមន្ត្រី ០២ រូប ជាជំនួយការឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១៨១

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៨ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះនាយទាហានជាន់ខ្ពស់ ចំនួន ១៣ រូប ១៨២

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០១៩ ស្តីពីការបញ្ចប់តំណែង ទីប្រឹក្សាលោកជំទាវ **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចំនួន ០២ រូប ១៨៣

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២០ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **ហួត ហាក់** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១៨៤

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២១ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងលោកជំទាវ ចំនួន ១០ រូប ១៨៥

០៩-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២២ ស្តីពីការតែងតាំងឯកឧត្តម **ថ្នាក់ ចាន់ធឿន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជំនួស ឯកឧត្តម **កែវ បូរ៉ាន្ត** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមអាយុ និងត្រូវបានប្រគល់ភារកិច្ច ជូនឯកឧត្តម **សំហេង បុរស** ឱ្យបំពេញមុខងារជាអគ្គាធិការនៃអគ្គាធិការដ្ឋាន ជំនួសឯកឧត្តម **ថ្នាក់ ចាន់ធឿន** ១៨៦

# II.រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការ បង្កើត ខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ ១៨៧
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្តីពីការ បង្កើត ស្រុករុក្ខគិរី នៃខេត្តបាត់ដំបង ១៩០
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពីការ ប្តូរខណ្ឌ នៃខេត្តប៉ៃលិនទៅជាក្រុង និង ជាស្រុក ១៩៣
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៦ អនក្រ.បក ស្តីពីការ ប្តូរខណ្ឌ នៃខេត្តកែបទៅជាក្រុង និង ជាស្រុក ១៩៥
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពីការ ប្តូរខណ្ឌ នៃខេត្តព្រះសីហនុទៅជាក្រុង និង ជាស្រុក ១៩៧
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពីការ ធ្វើអនុបយោគដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច ជូនក្រុមហ៊ុនឯកជន ធ្វើវិនិយោគកសិ-ឧស្សាហកម្ម នៅខេត្តបាត់ដំបង ២០០
០៩-០១-២០០៩ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការ ប្តូរឈ្មោះស្រុកព្រៃវែង ទៅជាស្រុកស្វាយអន្ទរ និងការបង្កើតក្រុងព្រៃវែង នៃខេត្តព្រៃវែង ២០៣
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការ ប្តូរឈ្មោះស្រុកក្រចេះ ទៅជាស្រុកចិត្របុរី និង ការបង្កើតក្រុងក្រចេះ នៃខេត្តក្រចេះ ២០៦
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពីការបង្កើតក្រុងព្រះវិហារ នៃខេត្តព្រះវិហារ ២០៩
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្វាយរៀង ទៅជាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង ២១២
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកសៀមរាប ទៅជាក្រុងសៀមរាប នៃខេត្តសៀមរាប ២១៥
០៩-០១-២០០៩ -អនុក្រឹត្យលេខ ៣០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៩
០៩-០១-២០០៩ -អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៣៥
០៩-០១-២០០៩ -អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៦៥
០៩-០១-២០០៩ -អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧០
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧១

## ២.សេចក្តីសំរេច

១២-០១-២០០៩ -សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការជ្រើសរើសពលទាហាន ២៧២

១២-០១-២០០៩ -សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យ បញ្ចុះខណ្ឌសីមាព្រះវិហារ និងសេនាសនៈវត្ត សន្សំកុសល ស្ថិតក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ២៧៣

## ៣.សារាចរ

១២-០១-២០០៩ -សារាចរលេខ ០១ សរ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ២៧៤

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃ ខែ ឆ្នាំ តាំងស៊ប់ |
|---|---|---|---|---|
| ១ | ជុំ ធីរៈ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ២ | នី កែវធារ៉ា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ៣ | ខ្លូង សុផល | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ៤ | យឹម ម៉ុសេង | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៥ | សរ បុរ៉ា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ៦ | នុត ចំណាន | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ៧ | ជា ផល្លា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |

មាត្រា ២ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃ ខែ ឆ្នាំ តាំងស៊ប់ |
|---|---|---|---|---|
| ១ | ស៊ាន សាន | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០៨-២០០៧ |
| ២ | សាន់ ទ៉ាលីន | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០៨-២០០៧ |
| ៣ | ម៉េង សុខជា | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០៨-២០០៧ |
| ៤ | កុយ ទ៉ាន់នី | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០១-២០០៨ |
| ៥ | ឯក ម៉េងលី | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០១-២០០៨ |
| ៦ | ឈុន គីរីវត្ថិ | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០១-២០០៨ |
| ៧ | ហាច រត្តនារី | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣ | ០១-០១-២០០៨ |
| ៨ | កើត សុបញ្ញា | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ៩ | ទី ពេជ្រ ប្រសិទ្ធ | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ១០ | ពិន យសសុជីវី | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ១១ | ជួន ទិមុល | ប | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |
| ១២ | ស៊ាន ទិជ្ជរី | ស | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤ | ០១-០៨-២០០៨ |

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ា.ល. ០៩០១.០១៦

លេខ : ៧៩ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ស៊ីនភេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្ត្រពីរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងមន្ត្រី ០២ រូប ជាជំនួយការឯកឧត្តម ញឹម វណ្ណដា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានរាយនាមខាងក្រោមនេះ :

១- ឯកឧត្តម **ញ៉ឹក ប៊ុនរិទ្ធ** មានឋានៈស្មើ អគ្គនាយក

២- ឯកឧត្តម **នាង ឆែន** មានឋានៈស្មើ អគ្គនាយក

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩*

*៣.ល. ០៩០១. ០១៧*

លេខ : *៧៨* ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី** *១៤* **ខែ** *មករា* **ឆ្នាំ២០០៩**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

[illegible] **ជិនកេន**

នស/រកត/០១០៩/០១៧

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

ចំពោះ :-

| | | | | | |
|---|---|---|---|---|---|
| ១-វរសេនីយ៍ទោ | គង់ សាមិត្ត | ០១០៥៩៣ | ១៤-វរសេនីយ៍ទោ | មេ សារឿង | ០១១៤៧៩ |
| ២-វរសេនីយ៍ទោ | ប្រាក់ ផាន | ០០៣៩៦៤ | ១៥-វរសេនីយ៍ទោ | ម៉ែន ម៉ុនសិរាន | ០១០៦០៥ |
| ៣-វរសេនីយ៍ទោ | ម៉ុន សារួន | ២១៩១០៧ | ១៦-វរសេនីយ៍ទោ | អ៊ុច តារា | ០២៩៦៧៣ |
| ៤-វរសេនីយ៍ទោ | រិទ្ធ រ៉ៃ | ០១០៨៦៦ | ១៧-វរសេនីយ៍ទោ | សួន សុន | ០០៥០០៨ |
| ៥-វរសេនីយ៍ទោ | ម៉ាក់ មុយ | ០២៥៧០៨ | ១៨-វរសេនីយ៍ទោ | លឹម សុផល | ០១៦០៦៧ |
| ៦-វរសេនីយ៍ទោ | ម៉ី ផាន់ណារ៉ុម | ០០៩០២១ | ១៩-វរសេនីយ៍ទោ | វណ្ណ សុភ័ណ្ឌ | ០០៤៩៩១ |
| ៧-វរសេនីយ៍ទោ | សរ សាវុធ | ០១០៦៣២ | ២០-វរសេនីយ៍ត្រី | តូច ចំនួតារា | ០៣០៨៣៥ |
| ៨-វរសេនីយ៍ទោ | ជួន សុខសារិន | ០១០៦២៥ | ២១-វរសេនីយ៍ត្រី | ម៉ៅ វិធ័យ | ០១៥៧៩៨ |
| ៩-វរសេនីយ៍ទោ | ផង់ ទ័យ | ០០៣៩៧៦ | ២២-វរសេនីយ៍ត្រី | យូរ សុខ | ០១១៤៩៩ |
| ១០-វរសេនីយ៍ទោ | អ៊ុន គឹមឈាន | ០០៣០០៨ | ២៣-វរសេនីយ៍ត្រី | ម៉ាំង សុខលុច | ១០៨៣៦៥ |
| ១១-វរសេនីយ៍ទោ | យៀប ឆៃរិន | ០០២១០៤ | ២៤-អនុសេនីយ៍ឯក | ឈុ ហាំងម៉ី | ២៣២៣៦៦ |
| ១២-វរសេនីយ៍ទោ | ម៉ែន សារិន | ០១០៦៤៩ | ២៥-លោក | អ៊ុង សួនស្មី | |
| ១៣-វរសេនីយ៍ទោ | ម៉ែន វណ្ណា | ០០១០៣៥ | ២៦-លោក | ឃុន សុផល | |

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

**នរោត្តម សីហមុនី**

៣រ.ឈ.០៩០១.០១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

លេខ : ៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់តំណែង ទីប្រឹក្សាលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចំនួន ០២រូប ដូចមាន រាយនាមខាងក្រោម:

១-ឯកឧត្តម ស្វូត្រ សុផល មានឋានៈស្មើអនុរដ្ឋលេខាធិការ

២-ឯកឧត្តម ហង្ស លុច មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩ល.០៩០១.០១៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩*

លេខៈ ៥៦ ច.ល.

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ឃុន ជិនកេន

នស/រកត/០១០៩/០២០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ហ្សូត ហាក់

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០១.០២០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ លេខ :៧៥ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០១០៩/០២១

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-
ឯកឧត្តម ឆេង សារឿន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-
១-ឯកឧត្តម ហ៊ុង ថៃម
២-ឯកឧត្តម ប្រាក់ ហម
៣-ឯកឧត្តម ស៊ុយ នូ
៤-ឯកឧត្តម ម៉ៅ សម្បត្តិ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-
១-ឯកឧត្តម កង ណែម
២-ឯកឧត្តម ពូ ដារ៉ានី

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-
១-ឯកឧត្តម ស៊ុំ រុំ
២-ឯកឧត្តម ឌុច សុវណ្ណារី
៣-លោកជំទាវ ឃុន លក្ស្មី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ : ៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩

រដ្ឋលេខាធិការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

៣៤.០៩០១.០២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ប្រាក់ ចាន់ធឿន ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំនួសឯកឧត្តម កែវ បូរ៉េន្ទ្រ ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមអាយុ ។

**មាត្រា ២ :** ប្រគល់ភារកិច្ច ជូនឯកឧត្តម សំហេង បុរស ឱ្យបំពេញមុខងារជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំនួសឯកឧត្តម ប្រាក់ ចាន់ធឿន ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.ល.០៩០១.០២២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

**មាត្រា ១.—**

ត្រូវបានបង្កើត **ខណ្ឌសែនសុខ** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៣ នៃខណ្ឌឫស្សីកែវ គឺ សង្កាត់ភ្នំពេញថ្មី សង្កាត់ទឹកថ្លា និងសង្កាត់ឃ្មួញ ។

មាត្រា ២.—

**ខណ្ឌសែនសុខ** មានសង្កាត់ចំនួន០៣គឺ សង្កាត់ភ្នំពេញថ្មី សង្កាត់ទឹកថ្លា និងសង្កាត់ឃ្មួញ ។

ព្រំប្រទល់រដ្ឋបាលនៃ **ខណ្ឌសែនសុខ** ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.—**

ទីតាំងសាលា **ខណ្ឌសែនសុខ** ស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី។

**មាត្រា ៤.—**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង **ខណ្ឌសែនសុខ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៥.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


4053Ha9938m²
6703Ha6960m²

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតស្រុករុក្ខគិរី នៃខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១២០៨/១៣៨២ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.—**

ត្រូវបានបង្កើត **ស្រុករុក្ខគិរី** នៃខេត្តបាត់ដំបង ដោយកាត់យកឃុំព្រៃត្រឡាច និងឃុំព្រែកជីក របស់ស្រុកមោងឫស្សី នៃខេត្តបាត់ដំបង ។

sub degree-bb

មាត្រា ២.—

**ស្រុករុក្ខគិរី** មានឃុំចំនួនពីរ គឺឃុំព្រៃត្រឡាច និងឃុំព្រែកជីក ។

ព្រំប្រទល់រដ្ឋបាលនៃ **ស្រុករុក្ខគិរី** ត្រូវបានកំណត់ដូចមានក្នុងផែនទី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៣.—

ទីតាំងសាលា **ស្រុករុក្ខគិរី** ស្ថិតនៅក្នុងភូមិព្រៃអម្ពូន់ ឃុំព្រៃត្រឡាច ។

មាត្រា ៤.—

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ស្រុករុក្ខគិរី** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ៥.—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៦.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| ចំណុច [illegible] | X | Y |
|---|---|---|
| 1 | 328322 | 1402810 |
| 2 | 330278 | 1401298 |
| 3 | 329007 | 1397413 |
| 4 | 332578 | 1396613 |
| 5 | 339071 | 1395369 |
| 6 | 351570 | 1389500 |
| 7 | 339538 | 1382658 |
| 8 | 339470 | 1382350 |
| 9 | 313555 | 1382311 |
| 10 | 313577 | 1386330 |
| 11 | 311925 | 1386344 |
| 12 | 309346 | 1384643 |
| 13 | 307645 | 1385444 |
| 14 | 311573 | 1383301 |
| 15 | 311591 | 1386794 |
| 16 | 312190 | 1397325 |
| 17 | 318099 | 1397316 |
| 18 | 321632 | 1402779 |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរខណ្ឌ នៃខេត្តប៉ៃលិនទៅជាក្រុង និង ជាស្រុក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្តូរក្រុងប៉ៃលិនទៅជាខេត្តប៉ៃលិន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

**មាត្រា ១ .—**

ត្រូវបានប្តូរខណ្ឌ នៃខេត្តប៉ៃលិន ទៅជាក្រុង និង ជាស្រុក ដូចខាងក្រោម :

- ខណ្ឌប៉ៃលិន ទៅជា ក្រុងប៉ៃលិន
- ខណ្ឌសាលាក្រៅ ទៅជា ស្រុកសាលាក្រៅ ។

**មាត្រា ២ .—**

ក្រុងប៉ៃលិន មានសង្កាត់ ០៤ គឺ :

- សង្កាត់ប៉ៃលិន
- សង្កាត់បរយ៉ាខា
- សង្កាត់ទួលល្វា
- សង្កាត់អូរតាវ៉ៅ ។

**មាត្រា ៣ .—**

ត្រូវបានប្ដូរសង្កាត់ នៃស្រុកសាលាក្រៅ ទៅជាឃុំ ដូចខាងក្រោម :

| | | |
|---|---|---|
| - សង្កាត់ស្ទឹងកាច់ | ទៅជា | ឃុំស្ទឹងកាច់ |
| - សង្កាត់សាលាក្រៅ | ទៅជា | ឃុំសាលាក្រៅ |
| - សង្កាត់អូរអណ្ដូង | ទៅជា | ឃុំអូរអណ្ដូង |
| - សង្កាត់ស្ទឹងត្រង់ | ទៅជា | ឃុំស្ទឹងត្រង់ ។ |

**មាត្រា ៤ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុង និង ស្រុក នៃខេត្តប៉ៃលិន ត្រូវអនុលោមទៅតាមច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តប៉ៃលិន អភិបាលក្រុង អភិបាលស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៦*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរខណ្ឌ នៃខេត្តកែបទៅជាក្រុង និង ជាស្រុក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៣ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្តូរក្រុងកែបទៅជាខេត្តកែប
- យោងតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១ .—**

ត្រូវបានប្តូរខណ្ឌ នៃខេត្តកែប ទៅជាក្រុង និង ជាស្រុក ដូចខាងក្រោម :

- ខណ្ឌកែប ទៅជា ក្រុងកែប
- ខណ្ឌដំណាក់ចង្អើរ ទៅជា ស្រុកដំណាក់ចង្អើរ ។

**មាត្រា ២ .—**

ក្រុងកែប មានសង្កាត់ ០២ គឺ :

- សង្កាត់កែប
- សង្កាត់ព្រៃធំ ។

**មាត្រា ៣ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកដំណាក់ចង្អើរ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់អង្កោល ទៅជា ឃុំអង្កោល
- សង្កាត់អូរក្រសារ ទៅជា ឃុំអូរក្រសារ
- សង្កាត់ពងទឹក ទៅជា ឃុំពងទឹក ។

**មាត្រា ៤ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង និង ស្រុក នៃខេត្តកែប ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកែប អភិបាលក្រុង អភិបាលស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរខណ្ឌ នៃខេត្តព្រះសីហនុទៅជាក្រុង និង ជាស្រុក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្តូរក្រុងព្រះសីហនុទៅជាខេត្តព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

**មាត្រា ១ .―**

ត្រូវបានប្តូរខណ្ឌ នៃខេត្តព្រះសីហនុ ទៅជាក្រុង និង ជាស្រុក ដូចខាងក្រោម :

- ខណ្ឌមិត្តភាព ទៅជា ក្រុងព្រះសីហនុ
- ខណ្ឌព្រៃនប់ ទៅជា ស្រុកព្រៃនប់
- ខណ្ឌស្ទឹងហាវ ទៅជា ស្រុកស្ទឹងហាវ ។

**មាត្រា ២ .—**

ក្រុងព្រះសីហនុ មានសង្កាត់ ០៥ គឺ :

- សង្កាត់លេខ ១
- សង្កាត់លេខ ២
- សង្កាត់លេខ ៣
- សង្កាត់លេខ ៤
- សង្កាត់កោះរ៉ុង ។

**មាត្រា ៣ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកព្រៃនប់ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់ទឹកថ្លា ទៅជា ឃុំទឹកថ្លា
- សង្កាត់ទឹកល្អក់ ទៅជា ឃុំទឹកល្អក់
- សង្កាត់សាមគ្គី ទៅជា ឃុំសាមគ្គី
- សង្កាត់ជើងគោ ទៅជា ឃុំជើងគោ
- សង្កាត់វាលរេញ ទៅជា ឃុំវាលរេញ
- សង្កាត់សំរុង ទៅជា ឃុំសំរុង
- សង្កាត់អណ្តូងថ្ម ទៅជា ឃុំអណ្តូងថ្ម
- សង្កាត់ទួលទទឹង ទៅជា ឃុំទួលទទឹង
- សង្កាត់ព្រៃនប់ ទៅជា ឃុំព្រៃនប់
- សង្កាត់អូរឧកញ៉ាហេង ទៅជា ឃុំអូរឧកញ៉ាហេង
- សង្កាត់បឹងតាព្រហ្ម ទៅជា ឃុំបឹងតាព្រហ្ម
- សង្កាត់អូរជ្រៅ ទៅជា ឃុំអូរជ្រៅ
- សង្កាត់រាម ទៅជា ឃុំរាម
- សង្កាត់បិតត្រាង ទៅជា ឃុំបិតត្រាង ។

**មាត្រា ៤ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកស្ទឹងហាវ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់អូរត្រេះ ទៅជា ឃុំអូរត្រេះ
- សង្កាត់ទំនប់រលក ទៅជា ឃុំទំនប់រលក
- សង្កាត់កំពេញ ទៅជា ឃុំកំពេញ ។

**មាត្រា ៥ .—**

ត្រូវបានបញ្ចូលផ្ទៃដី និង ប្រជាពលរដ្ឋ ដែលបានកាត់មកពីឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**មាត្រា ៦ .—**

ត្រូវបានបញ្ចូលផ្ទៃដី និង ប្រជាពលរដ្ឋ ដែលបានកាត់មកពីឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។

**មាត្រា ៧ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង និង ស្រុក នៃខេត្តព្រះសីហនុ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៨ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រះសីហនុ អភិបាលក្រុង អភិបាលស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ០១ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី* *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៧...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការធ្វើអនុបយោគដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការផ្ដល់ សម្បទានដីសេដ្ឋកិច្ច ជូនក្រុមហ៊ុនឯកជន ធ្វើវិនិយោគកសិ-ឧស្សាហកម្ម នៅខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពី គោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង

របស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការ ធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នៃដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ មានទំហំចំនួន ៥.២០០ ហិកតា ( ប្រាំពាន់ពីររយហិកតា) ដែលស្ថិតនៅក្នុងភូមិសាស្ត្រស្រុកសំឡូត ខេត្តបាត់ដំបង។ ទីតាំងបង្គោលដីត្រូវបានកំណត់ក្នុងផែនទីគោល ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ហើយមានចំណុចនិយាមកា ដូចខាងក្រោម ÷

A ( X : 252000 ; Y : 1389000 )

B ( X : 265000 ; Y : 1389000 )

C ( X : 265000 ; Y : 1385000 )

D ( X : 252000 ; Y : 1385000 )

**មាត្រា ២.-**

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ។

**មាត្រា ៣.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៥.២០០ ហិកតា ( ប្រាំពាន់ពីររយហិកតា) ដូចមានចែងក្នុងមាត្រាខាងលើ នៃអនុក្រឹត្យនេះ ដែលជាសម្បត្តិសាធារណរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា ៤.–**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ផ្តល់ជាសម្បទានដីសេដ្ឋកិច្ច ជូនក្រុមហ៊ុន វត្ថ័ សម្បត្តិ តាមគោលការណ៍ និងបទដ្ឋានកំណត់ របស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះស្រុកព្រៃវែង ទៅជាស្រុកស្វាយអន្ទរ និងការបង្កើតក្រុងព្រៃវែង នៃខេត្តព្រៃវែង

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះស្រុកព្រៃវែង ទៅជា **ស្រុកស្វាយអន្ទរ** នៃខេត្តព្រៃវែង។

មាត្រា ២.-

ត្រូវបានបង្កើត **ក្រុងព្រៃវែង** នៃខេត្តព្រៃវែង ដោយកាត់យកឃុំចំនួនបី គឺ ឃុំកំពង់លាវ ឃុំជើងទឹក និង ឃុំបារាយណ៍ ពីស្រុកកំពង់លាវ នៃខេត្តព្រៃវែង ។

ព្រំប្រទល់រដ្ឋបាលនៃ **ក្រុងព្រៃវែង** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំ ចំនួនបីនៃ **ក្រុងព្រៃវែង** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំកំពង់លាវ | ទៅជា | សង្កាត់កំពង់លាវ |
| ២- ឃុំបារាយណ៍ | ទៅជា | សង្កាត់បារាយណ៍ |
| ៣- ឃុំជើងទឹក | ទៅជា | សង្កាត់ជើងទឹក |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកកំពង់លាវ ដែលស្ថិតនៅក្នុងសង្កាត់កំពង់លាវ ទៅជាសាលា **ក្រុងព្រៃវែង** ។

**មាត្រា ៥.-**

ទីតាំងសាលាស្រុកកំពង់លាវ ត្រូវស្ថិតនៅក្នុងឃុំតាកោ ស្រុកកំពង់លាវ ខេត្តព្រៃវែង ។

**មាត្រា ៦.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងព្រៃវែង** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រៃវែង អភិបាលស្រុកស្វាយអន្ទរ អភិបាលក្រុងព្រៃវែង អភិបាលស្រុកកំពង់លាវ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




**បញ្ជាក់**
លេខៈ..........
បានឃើញ និង ឯកភាព
ក្រុងព្រៃវែង, ថ្ងៃទី.......ខែ.......ឆ្នាំ២០០៨
**អភិបាលខេត្ត**

អ៊ុង_សាមី

**បញ្ជាក់**
លេខៈ..........
បានពិនិត្យត្រឹមត្រូវ
គោរពជូនឯកឧត្តមអភិបាលខេត្តពិនិត្យសំរេច
ផ្ញើទៅថ្ងៃទី.......ខែ.......ឆ្នាំ២០០៨
**ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម**
**សំណង់ និងសុរិយោដីខេត្តព្រៃវែង**

ទិសូករ. នៃ_សុផល

**បញ្ជាក់**
លេខៈ..........
បានពិនិត្យ និង គោរពជូន
ឯកឧត្តមអភិបាលខេត្តពិនិត្យសំរេច
កំពង់លាវ, ថ្ងៃទី.......ខែ.......ឆ្នាំ២០០៨
**អភិបាលស្រុក**

កែវ_សេន

ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៨
**អ្នករៀបចំផែនទី**

**ហ៊ឿន រ៉ាវុធ**

លេខ..........
**បានឃើញ និង ឯកភាព**
ភ្នំពេញ, ថ្ងៃទី.......ខែ.......ឆ្នាំ២០០៩
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះស្រុកក្រចេះ ទៅជាស្រុកចិត្របុរី និងការបង្កើតក្រុងក្រចេះ នៃខេត្តក្រចេះ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះស្រុកក្រចេះ ទៅជា ស្រុកចិត្របុរី នៃខេត្តក្រចេះ។

**មាត្រា ២.-**

ត្រូវបានបង្កើត ក្រុងក្រចេះ នៃខេត្តក្រចេះ ដោយកាត់យកឃុំចំនួនប្រាំ គឺ ឃុំអូរឫស្សី ឃុំក្រចេះ

ឃុំកោះទ្រង់ ឃុំក្រគរ និង ឃុំរកាកណ្តាល ពីស្រុកចិត្របុរី ទៃខេត្តក្រចេះ ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងក្រចេះ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំ ចំនួនប្រាំនៃ ក្រុងក្រចេះ ឱ្យទៅជាសង្កាត់ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំ អូរឫស្សី | ទៅជា | សង្កាត់អូរឫស្សី |
| ២- ឃុំ ក្រចេះ | ទៅជា | សង្កាត់ក្រចេះ |
| ៣- ឃុំ កោះទ្រង់ | ទៅជា | សង្កាត់កោះទ្រង់ |
| ៤- ឃុំ ក្រគរ | ទៅជា | សង្កាត់ក្រគរ |
| ៥-ឃុំ រកាកណ្តាល | ទៅជា | សង្កាត់រកាកណ្តាល |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកចិត្របុរី ដែលស្ថិតនៅសង្កាត់អូរឫស្សី ទៅជាសាលា ក្រុងក្រចេះ ។

**មាត្រា ៥.-**

ទីតាំងសាលាស្រុកចិត្របុរី ត្រូវស្ថិតនៅក្នុងឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ ។

**មាត្រា ៦.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងក្រចេះ ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តក្រចេះ អភិបាលក្រុងក្រចេះ អភិបាលស្រុកចិត្របុរី និង ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




លេខ ០០៦ ឯ
បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ០៦ ខែ ០១ ឆ្នាំ ២០០៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង

| បានឃើញ និង ឯកភាព | បានឃើញ និង ឯកភាព | បានឃើញ និង ឯកភាព |
|---|---|---|
| ក្រចេះ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៨ | ក្រចេះ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៨ | ក្រចេះ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៨ |
| អភិបាលខេត្ត | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អភិបាលស្រុកក្រចេះ |
| ខាំ គឿន | ម៉ាន់ សជាត | ហៀ ស៊ុំយ៉េម |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុងព្រះវិហារ នៃខេត្តព្រះវិហារ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបង្កើត **ក្រុងព្រះវិហារ** នៃខេត្តព្រះវិហារ ដោយកាត់យកឃុំចំនួនពីរគឺ ឃុំកំពង់ប្រណាក និង ឃុំប៉ាលហាល ពីស្រុកត្បែងមានជ័យ នៃខេត្តព្រះវិហារ ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងព្រះវិហារ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្តូរឃុំ ចំនួនពីរនៃ **ក្រុងព្រះវិហារ** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

១- ឃុំកំពង់ប្រណាក ទៅជា សង្កាត់កំពង់ប្រណាក

២- ឃុំប៉ាលហាល ទៅជា សង្កាត់ប៉ាលហាល

**មាត្រា ៣.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកត្បែងមានជ័យ ដែលស្ថិតនៅក្នុងសង្កាត់កំពង់ប្រណាក ទៅជាសាលា **ក្រុងព្រះវិហារ** ។

**មាត្រា ៤.-**

ទីតាំងសាលាស្រុកត្បែងមានជ័យ ត្រូវស្ថិតនៅក្នុងឃុំប្រមេរុ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង **ក្រុងព្រះវិហារ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រះវិហារ អភិបាលក្រុងព្រះវិហារ អភិបាលស្រុកត្បែងមានជ័យ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

# ផែនទីបង្ហាញទីតាំងប្លង់ក្រុងព្រះវិហារ និងតំបន់រដ្ឋបាលទីប្រជុំជនស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ




លេខ : ១៤១ សហវ

បានឃើញ និងឯកភាព

ព្រះវិហារ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០០៨

អភិបាលខេត្តព្រះវិហារ

ព្រាប_តាន់

លេខ ១០៥

បានឃើញ និង ឯកភាព

ភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

លេខ :........២៣៤........ដ.ន.ស.ស

ត្បែងមានជ័យ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៨

សិក្សាដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ

គង់_សោភ័ណ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្វាយរៀង ទៅជាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកស្វាយរៀង ស្រុកស្វាយទាប ស្រុកកំពង់រោទិ៍ និងស្រុកស្វាយជ្រំ នៃខេត្តស្វាយរៀង ដោយកាត់យកឃុំចំនួនបី គឺ ឃុំសង្ឃ័រ ពីស្រុកស្វាយទាប ឃុំស្វាយតឿពីស្រុក កំពង់រោទិ៍ និងឃុំចេក ពីស្រុកស្វាយជ្រំ បញ្ចូលទៅក្នុងស្រុកស្វាយរៀង នៃខេត្តស្វាយរៀង។

**មាត្រា ២.-**

